

# ព្រះយេស៊ូវបានសុំយើងឲ្យចែកចាយដំណឹងល្អ

បន្ទាប់ពីទ្រង់បានមានព្រះជន្មឡើងវិញ ព្រះយេស៊ូវបានយាងទៅជួបពួកសាវករបស់ទ្រង់ ។ ទ្រង់បានប្រទានត្រី និងនំប៉័ងដល់ពួកគេបរិភោគ ។

ព្រះយេស៊ូវបានសួរទៅពេត្រុសថា « តើអ្នកស្រឡាញ់ខ្ញុំឬអី ? »

ពេត្រុសបានឆ្លើយថា ព្រះករុណាវិសេស ។ រួចព្រះយេស៊ូវបានមានបន្ទូលថា « ចូរឲ្យចំណីដល់កូនចៀមខ្ញុំស៊ីផង » ។

ព្រះយេស៊ូវបានសួរទៅពេត្រុស ពីរដងទៀត ។ « តើអ្នកស្រឡាញ់ខ្ញុំឬអី ? »

ពេត្រុសបានឆ្លើយថា ព្រះករុណាវិសេសទាំងពីរដង ។ ហើយទាំងពីរលើកនោះ ព្រះយេស៊ូវបានមានបន្ទូលថា « ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង » ។

ពេត្រុសបានស្វែងយល់ថា ព្រះយេស៊ូវបានសុំលោកឲ្យចែកចាយដំណឹងល្អ ។ ព្រះយេស៊ូវគឺជាអ្នកគង្វាល ហើយពួកយើងគឺជាចៀមរបស់ទ្រង់ ។

យើងអាចបង្ហាញសេចក្ដីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវ ដោយការជួយអ្នកដទៃឲ្យរៀនពីទ្រង់ ហើយដើរតាមទ្រង់ ។●

*អ្នកអាចអានដំណើររឿងនេះនៅក្នុង យ៉ូហាន ២១:១៥–១៧ ។*

សូមហែកទំព័រនេះចេញ ហើយបត់វាជាពីរ ។ បន្ទាប់មកសូមលើករូបភាពឡើងនៅពេលអ្នកនិទានរឿងនោះ ។




